ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកោះកុង
រដ្ឋបាលស្រុកកោះកុង
លេខ:....................រ.ប.ក

# របាយការណ៍ប្រចាំឆ្នាំ
# ស្តីពី
# ការអនុវត្តការងាររបស់រដ្ឋបាលស្រុកកោះកុង ឆ្នាំ២០២៣

# សេចក្តីផ្តើម

ស្រុកកោះកុង គឺជាស្រុកមួយក្នុងចំណោម ០១ក្រុង និង ០៦ ស្រុក នៃខេត្តកោះកុង ដែលមានព្រំប្រទល់ខាងលិចទល់នឹងស្រុកមណ្ឌលសីមា ខាងកើតទល់នឹងស្រុកបូទុមសាគរ ខាងជើងទល់នឹងស្រុកថ្មបាំង ខាងត្បូងទល់នឹងស្រុកគីរីសាគរ ក្នុងនោះស្រុកកោះកុងមាន ៖

| ល.រ | ការបរិយាយ | សរុប | ឯកតា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ១ ៥៤៩,២ | គីឡូម៉ែត្រការ៉េ |
| ២ | ចំនួនឃុំ | ០៤ | ឃុំ |
| ៣ | ចំនួនភូមិ | ១១ | ភូមិ |
| ៤ | ចំនួនគ្រួសារ | ២ ៤៣១ | គ្រួសារ |
| ៥ | ចំនួនប្រជាពលរដ្ឋសរុប | ៩១៨៥ | នាក់ |
| ៦ | ចំនួនស្ត្រីសរុប | ៤៤១៣ | នាក់ |

# ផ្នែកទី១

# លទ្ធផលការងារសម្រេចបាន

## ១.១.ការងាររដ្ឋបាល ស្ថិតិប្រជាពលរដ្ឋ និងហិរញ្ញវត្ថុ

### ១.១.១. ការងារលិខិត

នៅក្នុងឆ្នាំ២០២៣នេះ លិខិតស្នាមរបស់រដ្ឋបាលស្រុក និងឯកកសារប្រជាពលរដ្ឋ បានដាក់ចេញដូចមានខាងក្រោម៖

តារាងទី១៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ដីកាដែលបានដាក់ចេញ | | ២៤ | |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | | ៣១ | |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | | ២២៣៧ | |
| ៤ | លិខិតដែលបានទទួល | | ៥៥១ | |

### ១.១.២. ការស្ថិតិប្រជាពលរដ្ឋ

នៅក្នុង ខែតុលា ឆ្នាំ២០២៣ នេះ ការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋមានដូចខាងក្រោម៖

តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ

| ល.រ | ការបរិយាយ | សរុប | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្រួសារសរុប | ២ ៣៩១ | | |
| ២ | គ្រួសារអេចិន្ត្រៃយ៍ | ២ ៣៨៧ | | |
| ៣ | គ្រួសារបណ្តោះអាសន្ន | ១៩៤ | | |
| ៤ | ស្ត្រីជាមេគ្រួសារ | ១ ៧៨៥ | | |
| ៥ | ប្រជាពលរដ្ឋសរុប | ៩ ១៨៥ | ៤៤១៣ | |
| ៦ | កុមារអាយុក្រោម ៦ឆ្នាំ | ១៧៦ | ៧៧ | |
| ៧ | កុមារអាយុពី៦ឆ្នាំដល់១៨ឆ្នាំឡើង | ១ ៥៨៦ | ៧៩៩ | |
| ៨ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៥ ៨៤៨ | ២៨២០ | |

| | | | | |
|---|---|---|---|---|
| ៩ | ប្រជាពលរដ្ឋចំណាកស្រុកក្នុងប្រទេស | ២៦៦ | ៦៧ | |
| ១០ | ប្រជាពលរដ្ឋចំណាកស្រុកក្រៅប្រទេស | ៦៥៤ | ៣១៥ | |

**១.១.៣. ការងារអត្តសញ្ញាណកម្ម**

ការអនុវត្ត កិច្ចការ អត្រានុកូលដ្ឋាន និងការរក្សាសៀវភៅអត្រានុកូលដ្ឋាន ក្នុងឆ្នាំ២០២៣ នេះ អនុវត្តសេវា ទទួលបានប្រជាពលរដ្ឋ បានលទ្ធផលដូចខាងក្រោម៖

**តារាងទី៣៖ ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | សំបុត្រកំណើត | | ១៤៤ | |
| ២ | សេចក្តីចម្លងសំបុត្រកំណើត | | ៤៨៤ | |
| ៣ | សំបុត្របញ្ជាក់កំណើត | | ១៦៤ | |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | | ១៣៤៤ | |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍(ខ្មែរ និងខ្មែរ) | | ២១០ | |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍(ខ្មែរ និងខ្មែរ) | | ៧៧៨ | |
| ៧ | សំបុត្រអាពាហ៍ពិពាហ៍(ខ្មែរ និងបរទេស) | | ០០ | |
| ៨ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍(ខ្មែរ និងបរទេស) | | ០០ | |
| ៩ | សំបុត្រមរណភាព | | ២៧ | |
| ១០ | សេចក្តីចម្លងសំបុត្រមរណភាព | | ១០៣ | |
| **អត្តសញ្ញាណកម្ម** | | | | |
| ១ | សៀវភៅស្នាក់នៅ(ក២) | | ២៨១ | |
| ២ | សៀវភៅគ្រួសារ(ក៤) | | ៧៦ | |
| ៣ | អត្តសញ្ញាណបណ្ណ | | ៨៦១ | |
| | **សរុប** | | ១២១៨ | |

**១.១.៤.ការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ** (រួមទាំងការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល និងការងារចងសម្ព័ន្ធមេត្រីភាព

រដ្ឋបាលស្រុកបានផ្សព្វផ្សាយព័ត៌មានពីសកម្មភាពរបស់ថ្នាក់ដឹកនាំ និងសកម្មភាពរបស់មន្ត្រីតាមរយៈ ក្តារព័ត៌មាន និងបណ្តាញទំនាក់ទំនងសង្គម មានដូចខាងក្រោម៖

**តារាងទី៤៖ ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ**

| | ការបរិយាយ | ចំនួន (លើក) | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| **ក). ការផ្សព្វផ្សាយព័ត៌មាន** | | | | |
| ១ | វិទ្យុ | | ០០ | |
| ២ | ទូរទស្សន៍ | | ០១ | |
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | | ៤០ | |
| ៤ | ព្រឹត្តិបត្រព័ត៌មានទសន្សនាវដ្តី សារព័ត៌មាន | | ០០ | |
| ៥ | ផ្សេងៗ(ផ្សព្វផ្សាយតាម បណ្តាញសង្គម របស់រដ្ឋបាលស្រុក) | | ១១០ | |
| **ខ). ទំនាក់ទំនងសាធារណៈ** | | | | |

| | | | | |
|---|---|---|---|---|
| ១ | សាធារណជនមកទំនាក់ទំនងសាលាស្រុក | | ១៩៥០ | |
| ២ | គណៈប្រតិភូភ្ញៀវជាតិ | | ៤៩៥ | |
| ៣ | គណៈប្រតិភូអន្តរជាតិ | | ១៥៣ | |

## ១.១.៨ កាងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

### ក.ការងារហិរញ្ញវត្ថុ

ការអនុវត្តចំណូល ចំណាយ **ក្នុងឆ្នាំ២០២៣** នេះដូចខាងក្រោម៖

**តារាងទី៥៖ ការអនុវត្តចំណូល និងចំណាយ**

| ជំពូក | ចំណាត់ថ្នាក់ | ឥទានអនុញ្ញាត | ជាក់ស្តែង | ភាគរយ% |
|---|---|---|---|---|
| ក ផ្នែកចំណូល | | | | |
| ៧០ | ចំណូលសារពើពន្ធ | ០០ | ០០ | ០០ |
| ៧២ | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | ០០ | ០០ | ០០ |
| ៧៣ | ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា | ១០.០៣០.០០០ ៛ | ៣០០.០០០ ៛ | ២.៩៩ |
| ៧៤ | ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម | | | |
| ៧៥ | ការឧបត្ថម្ភធន(ឬការឧបត្ថម្ភអំណោយ) | ១.៦៦៦.១២០.០០០៛ | ១.៦៩៧.០០០.០០០ ៛ | ១០១.៨៥% |
| ៧៦ | ផលហិរញ្ញវត្ថុ | | ០០ | ០០ |
| ៧៧ | ផលផ្សេងៗ និងផលពិសេស | | ០០ | ០០ |
| | **សរុបចំណូល** | **១.៦៧៦.១៥០.០០០ ៛** | ១.៦៩៧.៣០០.០០០ ៛ | **១០១.២៦%** |
| ខ ផ្នែកចំណាយ | | | | |
| ៦០ | ការទិញ | ៦៥.១៧០.០០០៛ | ៦២.១៤០.៥០០៛ | ១៨.៣៥% |
| ៦១ | សេវាកម្ម | ៧៣៣.៩០០.០០០ ៛ | ៨០៧.៥៦២.០០០៛ | ១១០.០៣% |
| ៦២ | អត្ថប្រយោជន៍សង្គម | ១៤.០០០.០០០៛ | ៥.២៩០.០០០៛ | ៣៩.១៧% |
| ៦៣ | ពន្ធ និងអាករ | ០០ | ០០ | |
| ៦៤ | បន្ទុកបុគ្គលិក | ៧៩៣.៦៨០.០០០៛ | ៧៧៦.៥៩០.០០០៛ | ៩៧.៨៥% |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | ០០ | ០០ | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | ០០ | ០០ | |
| ៦៧ | បន្ទុកពិសេស | ០០ | ០០ | |
| ៦៨ | ទាយជ្ជទានឱ្យដល់ម្លេស់អចលកម្មរូបី | ០០ | ០០ | |
| ៦៩ | ចំណាយមិនបានគ្រោងទុក | ៦៩.៤០០.០០០៛ | ០០ | ០០% |
| ២០ | អចលកម្មអរូបី | ០០ | ០០ | |
| ២១ | អចលកម្មរូបី | ០០ | ០០ | |
| | **សរុបចំណាយ** | ១.៦៧៦.១៥០.០០០ ៛ | **១.៦៥១.៥៨២.៥០០ ៛** | ៩៨.៥៣% |

### ខ.ការគ្រប់គ្រងទ្រព្យសម្បត្តិ

ក្នុងខែឆ្នាំ២០២៣ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋអនុវត្ត ដូចខាងក្រោម៖

**តារាងទី៦៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ**

| ល.រ | ការបរិយាយ | ឯកតា | ចំនួន | ស្ថានភាព |
|---|---|---|---|---|

| | | | ដើមគ្រា | ក្នុងគ្រា | បូកយោង | |
|---|---|---|---|---|---|---|
| ១ | អចលនទ្រព្យ | | | | | |
| ១ | ដី | ទីតាំង | ០៥ | ០០ | ០៥ | |
| ៣ | អគារ | ទីតាំង | ០៥ | ០០ | ០៥ | |
| ៤ | ឧបករណ៍ សម្ភារ និងបរិក្ខារ( យានយន្ត ម៉ាស៊ីន គុ) | | | | | |
| ៥ | សម្ភារ និងសង្ហារឹម | គ្រឿង | ១៣៣ | ០០ | ១៣៣ | |

**១.១.៦ ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក**

រចនាសម្ព័ន្ធគ្រប់គ្រង រដ្ឋបាលស្រុកកោះកុង មានសមាសភាពសមាជិកក្រុមប្រឹក្សាស្រុក សរុបចំនួន១១រូប ស្រី០២រូប គណៈអភិបាលស្រុកចំនួន ០៧រូប ស្រី០១រូប និង នាយក នាយករងរដ្ឋបាល ប្រធាន អនុប្រធាន មន្ត្រី និង មន្ត្រីជាប់កិច្ចសន្យា សរុបចំនួន ២៥រូប ស្រី០៨រូប និង មានការិយាល័យ អង្គភាពចំណុះ ចំនួន១៣ ការិយាល័យ ។

**១.១.៦ ការរៀបចំនីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុសម្រាប់អង្គភាពរបស់រដ្ឋបាលស្រុកផ្អែកតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន**

រដ្ឋបាលស្រុកបានរៀបចំតាមនិតិវិធីរដ្ឋបាលតាមឋានានុក្រមការងារ និងរចនាសម្ព័ន្ធចាត់តាំង តាមតួនាទី ភារកិច្ច ដែលបានកំណត់ច្បាស់លាស់ ។ ចំពោះការងារហិរញ្ញវត្ថុ បានអនុវត្តតាមការណែនាំ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតំកល់គំរូហត្ថលេខានៅ រតនាគារខេត្ត និង នៅធនាគារអេស៊ីលីដា ដែលអភិបាលស្រុកជាអាណាប័ក និងបានអនុវត្តការងារដូចខាងក្រោមៈ

- បានទូទាត់បេសកម្មជូនថ្នាក់ដឹកនាំ ក្រុមប្រឹក្សា មន្ត្រី និងមន្ត្រីជាប់កិច្ចសន្យាបានចំនួន ០៣ លើក
- បានទូទាត់បេសកម្មជូនការិយាល័យអប់រំ យុវជន និងកីឡា ចុះតាមសាលារៀនចំនួន ០៣ លើក
- បានទូទាត់បៀវត្សប្រចាំខែមករា-ធ្នូ ឆ្នាំ២០២៣ ជូនថ្នាកដឹកនាំ ក្រុមប្រឹក្សា មន្ត្រី និងមន្ត្រីជាប់កិច្ចសន្យា
- បានបើកប្រាក់រង្វាន់ទេយ្យបុរេប្រទាន និងទូទាត់បានចំនួន ០៣ លើក ក្នុង ឆ្នាំ២០២៣
- បានរៀបចំឯកសារជានាចំណាយ និងទូទាត់ ទំនិញ និងប្រេង ឆ្នាំ២០២៣
- បានរៀបចំឯកសារជានាចំណាយ និងទូទាត់ថវិកា ផ្លូវបេតុងអាមេ ក្នុង ឃុំកោះកាពិ ស្រុកកោះកុង សម្រាប់ថវិកាឆ្នាំ២០២៣
- បានរៀបចំស្នើតុល្យភាពត្រីមាសបានចំនួន ០២ លើក គឺលើកទី២ និងលើកទី៤ ឆ្នាំ២០២៣
- បានបែកចែកប្រាក់រង្វាន់ប្រចាំត្រីមាសទី១ ទី២ និងត្រីមាសទី៣ ឆ្នាំ២០២៣
- បាននិយ័តភាពថវិកាក្នុងជំពូក ០២ លើក និងក្រៅជំពូក ០១លើកៗ
- បានទូទាត់បេសកកម្មជូនថ្នាក់ដឹកនាំ ក្រុមប្រឹក្សា មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាបានចំនួន ០៣ លើក
- បានអនុវត្តការងារអោហារូបត្ថម្ភនៅកម្ពុជាលើការងារហិរញ្ញវត្ថុ
- បានទូទាត់អគ្គីសនីចំនួន ០២ លើក
- ទូទាត់ប្រាក់សោធនមន្ត្រីរាជការចូលនិវត្តន៍ចំនួន ០២ លើក
- ទូទាត់ប្រាក់ជូនមន្ត្រីសម្រាលកូន ០១ លើក
- ទូទាត់ប្រាក់សមាគមន៍មន្ត្រីរាជការចំនួន ០១ លើក
- ទទួលសាវនកម្មចំនួន ០២ លើក
- បានបិទបញ្ជីចំណូលចំណាយ ថវិកា ឆ្នាំ២០២២
- បានរៀបចំគ្រោងថវិកាឆ្នាំ២០២៣

**១.១.៨ ការងារសណ្តាប់ធ្នាប់សាធារណៈ:**

១. មានក្រុមការងារគណៈបញ្ជាការឯកភាព នៃរដ្ឋបាលស្រុកកោះកុង ដែលមានលេខាធិការដ្ឋានជាជំនួយការបានដឹកនាំកិច្ចប្រជុំប្រចាំខែតុលា ឆ្នាំ២០២៣ លេខាធិការដ្ឋាន នៃគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុកកោះកុង និងមានកងកម្លាំងទាំង៣ប្រភេទ ជាសេនាធិការ ក្នុងការការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅក្នុងដែនសមត្ថកិច្ចរដ្ឋបាលស្រុកកោះកុង ដោយបានបែងចែកវេនប្រចាំការល្បាត២៤ លើ២៤ម៉ោង តាមគោលដៅនីមួយៗ ។

២. កម្លាំងជំនាញបានចុះធ្វើវេទិកាសាធារណៈផ្សព្វផ្សាយអំពីគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពទាំង៧ចំណុចនៅតាមភូមិទាំង១១ ក្នុងឃុំទាំង៤ នៃស្រុកកោះកុង ។

៣. ក្រុមលេខាធិការដ្ឋានដឹកនាំដោយ លោក ណឹម ភិរម្យ អភិបាលរងស្រុក បានប្រជុំបូកសរុបរបាយការណ៍គណៈបញ្ជាការឯកភាពស្រុកកោះកុង ប្រចាំខែតុលា ឆ្នាំ២០២៣ ។

១.១.៩ ការងាររបាយការណ៍ប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ រដ្ឋបាលស្រុក

-បានរៀបចំរបាយការណ៍ឆ្នាំ២០២៣ របស់រដ្ឋបាលស្រុកដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត

## ១.២.ការងារគណៈអភិបាល និងនាយករដ្ឋបាល

### ១.២.១ ការងារគណៈអភិបាល

លោក ជា សូរី អភិបាលស្រុក បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ៥២ លើក ។

លោកស្រី អ៊ិន សុភី អភិបាលរងស្រុក បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ៥៩ លើក ។

លោក ណឹម ភិរម្យ អភិបាលរងស្រុក បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ៤៩ លើក ។

លោក ហួត សារឹម អភិបាលរងស្រុក បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ២៦ លើក ។

លោក សំ សំអុល អភិបាលរងស្រុក បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ៤៤ លើក ។

លោក លីម ភឿន អភិបាលរងស្រុក បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ២០ លើក ។

លោកហែមប៊ុនសំបូរអភិបាលរងស្រុក បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ៣៨ លើក ។

### ១.២.២ ការងារនាយក នាយករងរដ្ឋបាល

លោក សែម សំអាង នាយករដ្ឋបាល បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ២៦ លើក ។

លោក សន សេង នាយករងរដ្ឋបាល បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ៣៥ លើក ។

លោកស្រី សេងគីមហ៊ួននាយករងរដ្ឋបាល បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ២២ លើក ។

តារាងទី៧៖ កិច្ចប្រជុំគណៈអភិបាល

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា (លើក) | ក្នុងគ្រា (លើក) | បូកយោង (លើក) |
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ០០ | ០២ | ០២ |
| ២ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | ០០ | ០០ | ០០ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់គណអភិបាល | ០០ | ០០ | ០០ |

១.៣.ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

### ១.៣.១ ការងារក្រុមប្រឹក្សា

លោក ឯក ម៉ឹង ប្រធានក្រុមប្រឹក្សាស្រុក បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ៥១ លើក ។

លោក កាយ អួយ សមាជិកក្រុមប្រឹក្សា បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ២៥ លើក ។

លោក ជុំ ឈឺន សមាជិកក្រុមប្រឹក្សា បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ១៥ លើក ។

លោកស្រី សឿ សារី សមាជិកក្រុមប្រឹក្សា បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ៣៤ លើក ។

លោក អ៊ឹង ទូច សមាជិកក្រុមប្រឹក្សា បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ២៩ លើក ។

លោក ម៉ាក្ស វឹង សមាជិកក្រុមប្រឹក្សា បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ១៧ លើក ។

**លោក ទឹម ផេង សមាជិកក្រុមប្រឹក្សា** បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ២១ លើក ។
**លោកស្រី ជឿន ពិសី សមាជិកក្រុមប្រឹក្សា** បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ២២ លើក ។
**លោក ហៀង ហួន សមាជិកក្រុមប្រឹក្សា** បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ១៧ លើក ។
**លោក ពុទ្ធិ សែន សមាជិកក្រុមប្រឹក្សា** បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ១៦ លើក ។
**លោក អ៊ុំ ពៅ សមាជិកក្រុមប្រឹក្សា** បានអញ្ជើញ ចូលរួមប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ សរុបចំនួន ១៤ លើក ។

តារាងទី៨៖ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា (លើក) | ក្នុងគ្រា (លើក) | បូកយោង (លើក) |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១១ | ០១ | ១២ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ០៣ | ០០ | ០៣ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០០ | ០០ | ០០ |

## ១.៤. ការងារគណៈកម្មាធិការ និងគណៈកម្មការ

តារាងទី៩៖ កិច្ចប្រជុំគណៈកម្មាធិការ និងគណៈកម្មការ

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា (លើក) | ក្នុងគ្រា (លើក) | បូកយោង (លើក) |
| ១ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ០៦ | ០១ | ០៧ |
| ២ | កិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម | ០៣ | ០១ | ០៤ |
| ៣ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ០៧ | ០១ | ០៨ |

## ១.៤. ការងារលេខាធិការក្រុមប្រឹក្សាស្រុក

**លោក ប៊ុន វិបុត្រ ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សា** បានចូលរួមប្រជុំ និងកម្មវិធីផ្សេងចំនួន២៥លើក។

### ១.៤.១ ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា

- យោងតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាស្រុកបានរៀបចំប្រតិទិន្នសម្រាប់កិច្ចប្រជុំដែលបានដាក់ឆ្លងក្រុមប្រឹក្សាអនុម័ត ដែលមាននាយករដ្ឋបាលសាលាស្រុក ការិយាល័យលេខាធិការក្រុមប្រឹក្សា និងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ជាសេនាធិការលើដំណើការរៀបចំកិច្ចប្រជុំ ។

### ១.៤.២ ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា

- បានរៀបចំកំណត់ហេតុកិច្ចប្រជុំសាមញ្ញលើកទី៤៣-៥៤ និងកិច្ចប្រជុំវិសាមញ្ញលើកទី៩ អណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុកកោះកុង ។

### ១.៤.៣ ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានារបស់ក្រុមប្រឹក្សា

-បានផ្សព្វផ្សាយ ជូនដំណឹងស្តីពីកិច្ចប្រជុំសាមញ្ញលើកទី៤៣-៥៤ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុកកោះកុង ចំនួន ១២លើក

### ១.៤.៤ ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា

-បានរក្សាទុកកំណត់ហេតុរាល់កិច្ចប្រជុំ និងឯកសារនានារបស់ក្រុមប្រឹក្សា ដែលបានដាក់ឆ្លងក្រុមប្រឹក្សាពិនិត្យ និងអនុម័ត បញ្ជូនទៅរដ្ឋបាលខេត្ត និងរៀបចំទុកដាក់ឯកសាររាល់កិច្ចប្រជុំក្រុមប្រឹក្សាបានត្រឹមត្រូវ

## ១.៥ ការងាររៀបចំវេទិកា

តារាងទី១០ ៖ ការរៀបចំវេទិកា

| ល.រ | ឈ្មោះវេទិកា | អ្នកចូលរួម |
|---|---|---|

| | | សរុប | ស្រី |
|---|---|---|---|
| ១ | វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ | ១១៧ | ៥១ |
| ២ | វេទិកាផ្សេងៗ(គ្មាន) | ០០ | ០០ |

## ១.៦.អង្គភាពលទ្ធកម្ម

តារាងទី១១៖ ការងារលទ្ធកម្ម

| ល.រ | ការបរិយាយ | បរិមាណ | វិធីសាស្ត្រ | តម្លៃប៉ាន់ស្មាន (រៀល) | តម្លៃកិច្ចសន្យា (រៀល) | វឌ្ឍនភាព |
|---|---|---|---|---|---|---|
| ក.ផ្នែកទំនិញ | | | | | | |
| ១ | សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ | ៩៥ | ស្ទង់តម្លៃ | ២.០០០.៣០០ | ២.០០០.៣០០ | ប្រគល់ទទួលបញ្ចប់ ១០០% |
| ២ | ប្រេងឥន្ធនៈ និងប្រេងរំអិល | ៤៣៧៥ . លីត្រ | ពិគ្រោះថ្លៃ | ១៩.៥០០.០០០ | ១៩.៥០០.០០០ | ប្រគល់ទទួលបញ្ចប់ ១០០% |
| ៣ | សម្ភារៈការិយាល័យ | ២២៩ | ពិគ្រោះថ្លៃ | ១០,៥០០,០០០ | ១០,៥០០,០០០ | ប្រគល់ទទួលបញ្ចប់ ១០០% |
| ៤ | បរិក្ខានិងបច្ចេកទេសមិនមែនព័ត៌មានវិទ្យា | ២ | ស្ទង់ថ្លៃ | ២,៤៥០,០០០ | ២,៤៥០,០០០ | ប្រគល់ទទួលបញ្ចប់ ១០០% |
| ៥ | សង្ហារឹម | ៣២ | ស្ទង់ថ្លៃ | ៣,១២០,០០០ | ៣,១២០,០០០ | ប្រគល់ទទួលបញ្ចប់ ១០០% |
| ៦ | សម្ភារៈប្រើប្រាស់ | ២៧ | ស្ទង់តម្លៃ | ៣,៨៥០,០០០ | ៣,៨៥០,០០០ | ប្រគល់ទទួលបញ្ចប់ ១០០% |
| ៧ | សម្ភារៈនិងបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យា | ៥ | ស្ទង់តម្លៃ | ៦,៩៥០,០០០ | ៦,៩៥០,០០០ | ប្រគល់ទទួលបញ្ចប់ ១០០% |
| ខ.ផ្នែកសេវាកម្ម | | | | | | |
| | គ្មាន | | | | | |
| គ.ផ្នែកសំណង់ស៊ីវិល | | | | | | |
| ១ | ការថែទាំជួសជុលផ្លូវបេតុង | ១ខ្សែ | ដេញថ្លៃ | ៦៥២,១៨០,០០០ | ៦៥១,២៧៣,០០០ | បានរៀបចំពិធីប្រគល់ទទួលគម្រោង១០០% រួចរាល់ |

១.៦.២.ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ផ្តល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ

- បានចុះផ្សាយព័ត៌មាន និងជូនដំណឹង អំពីកាលបរិច្ឆេទ និងពេលវេលា នៃដំណើរការដេញថ្លៃ
- បានរៀបចំទុកដាក់សំណុំឯកសារដេញថ្លៃ
- បានរៀបចំទីកន្លែង និងរៀបចំឯកសារបើកសំណើដេញថ្លៃ

១.៦.៣.ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ

- បានរៀបចំរបាយការណ៍ និងកំណត់ហេតុ ស្តីពីការបើកសំណើដេញថ្លៃដើម្បីដាក់ឆ្លងគណៈកម្មាធិការលទ្ធកម្មពិនិត្យ និងអនុម័ត

១.៦.៤.ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេស នៃសំណើដេញថ្លៃ

- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម ដើម្បីធ្វើការសម្របសម្រួលក្នុងការវាយតម្លៃបច្ចេកទេស នៃ សំណើដេញថ្លៃ

១.៦.៥.ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា

- បានរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងដាក់ឆ្លងគណៈកម្មាធិការលទ្ធកម្ម ដើម្បីពិនិត្យ និងផ្តល់យោបល់
- បានចេញសេចក្តីជូនដំណឹង ស្តីពីការផ្តល់កិច្ចសន្យាដល់ក្រុមហ៊ុន **កក់ ស៊ុនសេង** ដែលបានដេញថ្លៃឈ្នះ

១.៦.៦.ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម

- បានចូលរួមពិធីបើកការដ្ឋានគម្រោងជួសជុលផ្លូវបេតុងអាមេចំនួន ០១ ខ្សែ ប្រវែង ១,០០៥ម៉ែត្រ ទទឹង៣ម៉ែត្រ និងកម្រាស់ ១២០ មម នៅភូមិ១ ឃុំកោះកាពិ ស្រុកកោះកុង ខេត្តកោះកុង ក្រោមអធិបតីភាព លោកស្រី **អ៊ិន សុភី** អភិបាលរងស្រុក និងជាអនុប្រធានគណៈកម្មាធិការលទ្ធកម្ម ស្រុកកោះកុង ។
- បានចូលរួមពិធីប្រគល់ទទួលគម្រោងជួសជុលផ្លូវបេតុងអាមេចំនួន ០១ ខ្សែ ប្រវែង ១,០០៥ ម៉ែត្រ ទទឹងប្រវែង ៣ ម៉ែត្រ និងកម្រាស់១២០ មម ស្ថិតក្រោមអធិបតីភាព លោក **ជា សូវី** អភិបាល នៃគណៈអភិបាល និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម ស្រុកកោះកុង ដែលសមាសភាព អញ្ជើញចូលរួមសរុបចំនួន ១១ នាក់ ស្រី ០ នាក់ នៅសាលប្រជុំ សាលាស្រុកកោះកុង ។
- គណៈកម្មាធិការលទ្ធកម្មស្រុកបានធ្វើការប្រជុំតាមដាន និងត្រួតពិនិត្យ វឌ្ឍនភាព នៃការអនុវត្តគម្រោងរបស់ ក្រុមហ៊ុន បាន ចំនួន ២ លើក

## ១.៧ ការគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

១.៧.១. ការគ្រប់គ្រងបុគ្គលិក

ការគ្រប់គ្រងបុគ្គលិក ក្រុមប្រឹក្សា គណៈអភិបាល មន្ត្រី និងមន្ត្រីកិច្ចសន្យា ក្នុងក្របខណ្ឌ រចនាសម្ព័ន្ធរបស់ រដ្ឋបាលស្រុក ក្នុងឆ្នាំ២០២៣ នេះមានដូចខាងក្រោម៖

តារាងទី១២៖ ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក

| ល.រ | ការបរិយាយ | សរុប | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| **ក** | **ក្រុមប្រឹក្សា និងការិយាល័យប្រជាពលរដ្ឋ** | | | |
| ១ | ប្រធានក្រុមប្រឹក្សា | ០១ | ០០ | |
| ២ | សមាជិកក្រុមប្រឹក្សា | ១១ | ០២ | |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ០០ | ០០ | |
| ៤ | ប្រធានការិយាល័យប្រជាពលរដ្ឋ | ០១ | ០០ | |
| ៥ | បុគ្គលិកជំនួយការការិយាល័យប្រជាពលរដ្ឋ | ០១ | ០០ | |
| **ខ** | **គណៈអភិបាល និងបុគ្គលិក** | | | |
| ៦ | អភិបាល | ០១ | ០០ | |
| ៧ | អភិបាលរង | ០៦ | ០១ | |
| ៨ | នាយករដ្ឋបាល | ០១ | ០០ | |

| ល.រ | ការបរិយាយ | សរុប | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| ៩ | នាយករងរដ្ឋបាល | ០២ | ០១ | |
| ១០ | ប្រធានការិយាល័យ និងអង្គភាព | ០៨ | ០១ | |
| ១១ | អនុប្រធានការិយាល័យ និងអង្គភាព | ០៨ | ០២ | |
| ១២ | មន្ត្រីការិយាល័យ | ០៤ | ០៣ | កម្មសិក្សា០២ |
| ១៣ | បុគ្គលិកកិច្ចសន្យា | ០៣ | ០១ | |
| ១៤ | បុគ្គលិកស្ម័គ្រចិត្ត | ០៦ | ០៤ | |

### ១.៧.២. ការអភិវឌ្ឍធនធានមនុស្ស

ក្នុងឆ្នាំនេះដើម្បីពង្រឹងនូវសមត្ថភាពមន្ត្រីឲ្យកាន់តែមានសមត្ថភាពក្នុងការបំពេញការងារឲ្យមានប្រសិទ្ធិភាពខ្ពស់រដ្ឋបាលស្រុកបានចាត់តាំងមន្ត្រីឱ្យចូលរួមវគ្គបណ្តុះបណ្តាលខាងក្រោមនេះ៖

**តារាងទី១៣៖ការកសាងសមត្ថភាព**

| ល.រ | ឈ្មោះវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| ១ | សិក្ខាសាលាផ្សព្វផ្សាយ អនុក្រឹត្យស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជូនដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ | ០១ | ០២ | ០០ | **រដ្ឋបាលខេត្ត** |
| ២ | កិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីយន្តការ និងតួនាទីភារកិច្ចរបស់មន្ត្រីទទួលបន្ទុកការងារគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | ០១ | ០២ | ០១ | **រដ្ឋបាលខេត្ត** |
| ៣ | សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ទស្សនទាន អត្ថប្រយោជន៍ និងនីតិវិធីការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្តាមថ្មកោះកុង និងការចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃអំពីផលិតផលសក្តានុពល ក្តាមថ្មកោះកុង ក្នុងខេត្តកោះកុង | ០១ | ០១ | ០០ | **រដ្ឋបាលខេត្ត** |
| ៤ | វគ្គបណ្តុះបណ្តាល ស្តីពីការបំពេញកម្រងសំណួរឃុំ សង្កាត់ ក្នុងប្រព័ន្ធកូបូ ដល់មន្ត្រីពាក់ព័ន្ធនៅរដ្ឋបាលឃុំ សង្កាត់ លើការតាមដានការអនុវត្តសេចក្តីណែនាំលេខ០២៥ ស.ជ.ណ ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងអនុម័តថវិការបស់រដ្ឋបាលឃុំ សង្កាត់ | ០១ | ០១ | ០០ | **រដ្ឋបាលខេត្ត** |
| ៥ | សិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច និងអនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ | ០១ | ០១ | ០០ | **រដ្ឋបាលខេត្ត** |
| ៦ | សិក្ខាសាលាបូកសរុបលទ្ធផល និងការពិគ្រោះយោបល់អំពីការផ្តល់សេវារដ្ឋបាល និងការសម្រុះសម្រួលដោះស្រាយ បណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ឆ្នាំ២០១៨ ដល់ឆ្នាំ២០២២) | ០២ | ០២ | ០១ | **ក្រសួង** |
| ៧ | វគ្គសិក្ខាសាលាណែនាំ ស្តីពីការប្រឹក្សាគរុកោសល្យថ្នាក់ដំបូងជូនដល់ទីប្រឹក្សាជំនាញ និងទីប្រឹក្សាគរុកោសល្យប្រចាំសាលារៀនសម្រាប់ផ្តល់ប្រឹក្សាដល់គ្រូបង្រៀនថ្នាក់ទី១ | ០២ | ០២ | ០០ | **មន្ទីរអប់រំ យុវជន និងកីឡា** |

| | | | | | |
|---|---|---|---|---|---|
| ៨ | សិក្ខាសាលាស្តីពី ការអភិវឌ្ឍបណ្ណាល័យសាលារៀន និងរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៨ ក្រោមប្រធានបទ អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ | ០២ | ០២ | ០០ | **វិទ្យាស្ថានបច្ចេកទេសកម្ពុជា (សាលាតិចណូ)** |
| ៩ | សិក្ខាសាលាប្រឹក្សាយោបល់ពាក់ព័ន្ធនឹង ការពង្រឹងសមត្ថភាពអ្នកផលិត និងកែច្នៃផលិតផល ក្នុងការស្វែងរកទីផ្សារក្នុង និងក្រៅប្រទេស | ០១ | ០១ | ០០ | **មន្ទីរពាណិជ្ជកម្មខេត្តកោះកុង** |
| ១០ | សិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ សម្រាប់រដ្ឋបាលស្រុក | ០១ | ០២ | ០១ | **ក្រសួង** |
| ១១ | សិក្ខាសាលា ពង្រឹងការអនុវត្តគោលការណ៍ណែនាំអនុវត្តលក្ខខណ្ឌអប្បបរមាទឹកស្អាត និងអនាម័យនៅតាមគ្រឹះស្ថានសិក្សា | ០២ | ០១ | ០១ | **មន្ទីរអប់រំ យុវជន និងកីឡា** |
| ១២ | សិក្ខាសាលាស្តីពី ទិសដៅនៃការពង្រឹងយន្តការ និងគោលការនយោបាយព័ត៌មាន | ០២ | ០១ | ០០ | **ក្រសួង** |
| ១៣ | សិក្ខាសាលា ទិវាសហប្រជាជាតិស្តីពីសប្តាហ៍សុខដុមនីយកម្ម អន្តរជំនឿសាសនាពិភពលោកលើកទី១៣ ក្រោមប្រធានបទ អន្តរជំនឿសាសនា ដើម្បីកិច្ចការពារបរិស្ថាន និងទេសចរណ៍សាសនា នៅមជ្ឈមណ្ឌល ស៊ូននីង | ០១ | ០២ | ០០ | **មន្ទីរធម្មការ និងសាសនាខេត្តកោះកុង** |
| ១៤ | សិក្ខាសាលា ស្តីពីការគ្រប់គ្រងប្រតិបត្តិការទីលានទុកដាក់សំរាមសំណល់រឹង | ០១ | ០១ | ០០ | ក្រសួងមហាផ្ទៃ |
| ១៥ | វគ្គសិក្ខាសាលាស្តីពី ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា លើមុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ក្នុងឆ្នាំ២០២៣។ | ០៤ | ០២ | ០២ | ក្រសួងអប់រំយុវជន និងកីឡា |
| ១៦ | វគ្គបណ្តុះបណ្តាលស្តីពីការហ្វឹកហ្វឺនសម្រាប់មូលនិធិគាំទ្រផ្តល់សេវាឃុំសង្កាត់ នៃគម្រោងអាហារូបត្ថម្ភនៅកម្ពុជា | ០៣ | ០៤ | ០២ | គ.ជ.អ.ប |
| ១៧ | កិច្ចប្រជុំផ្សព្វផ្សាយ ខ្លឹមសារសំខាន់ៗ នៃលិខិតបទដ្ឋានគតិយុទ្ធមួយចំនួនពាក់ព័ន្ធនឹងការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិជូនដល់រដ្ឋបាលក្រុង ស្រុក | ០១ | ៣០ | ០៤ | រដ្ឋបាលស្រុក |
| ១៨ | សិក្ខាសាលាផ្សព្វផ្សាយអំពីកិច្ចការរដ្ឋបាលរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក | ០១ | ០២ | ០០ | រដ្ឋបាលខេត្តកោះកុង |
| ១៩ | វគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងយន្តការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងអត្រាឧបត្ថម្ភថ្មី | ០១ | ០២ | ០២ | រដ្ឋបាលខេត្តកោះកុង |
| ២០ | ចូលរួមកម្មវិធីបណ្តុះបណ្តាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ | ០១ | ០១ | ០០ | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកោះកុង |
| ២១ | វគ្គបណ្តុះបណ្តាល ស្តីពីគោលការណ៍បែបបទ និងនីតិវិធីនៃការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ០១ | ០៣ | ០០ | រដ្ឋបាលខេត្តកោះកុង |
| ២២ | សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនជូនដល់សមាជិកនៃគណៈកម្មការរៀបចំ និងគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនខេត្តកោះកុង | ០១ | ០៣ | ០០ | រដ្ឋបាលខេត្តកោះកុង |

| | | | | | |
|---|---|---|---|---|---|
| ២៣ | វគ្គបណ្តុះបណ្តាលស្តីពី ការរៀបចំគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឆ្នាំ២០២៤ និងផ្សព្វផ្សាយអនុក្រឹត្យស្តីពី ការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ | ០៣ | ០២ | ០០ | ក្រសួងមហាផ្ទៃ |
| ២៤ | សិក្ខាសាលា បញ្ជ្រាបការយល់ដឹងអំពីគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីហិរញ្ញវត្ថុសម្រាប់អនុវត្តកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន | ០២ | ០៣ | ០០ | ក្រសួងបរិស្ថាន |
| ២៥ | សិក្ខាសាលា បណ្តុះបណ្តាល ស្តីពីការវាយតម្លៃសេវាកម្មអេកូឡូស៊ីតំបន់ដីសើមនៅកម្ពុជា | ០២ | ០១ | ០០ | ក្រសួងបរិស្ថាន |
| ២៦ | វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ក្រោមជាតិលើសៀវភៅណែនាំស្តីពីកាអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព | ០១ | ០១ | ០០ | ក្រសួងមហាផ្ទៃ |
| ២៧ | វគ្គបណ្តុះ បណ្តាលរំលឹកឡើងវិញអំពីការប្រើប្រាស់ប្រព័ន្ធប្រកាសឱ្យដឹងមុន | ០១ | ០២ | ០០ | រដ្ឋបាលខេត្តកោះកុង |
| ២៨ | វគ្គបណ្តុះបណ្តាលរំលឹកស្តីពី ការកំណត់អត្តសញ្ញាណកម្ម ជនមានពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន | ០១ | ០២ | ០១ | រដ្ឋបាលខេត្តកោះកុង |
| ២៩ | វគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៣ | ០២ | ០១ | ០០ | រដ្ឋបាលខេត្តកោះកុង |
| ៣០ | វគ្គសិក្ខាសាលាថ្នាក់ជាតិស្តីពី ការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន ដែលមានភាពធន់នៅតាមសាលារៀនក្នុងប្រទេសកម្ពុជា | ០១ | ០១ | ០០ | អង្គការ សកម្មភាពដៃគូសម្រាប់អភិវឌ្ឍន៍ |
| ៣១ | វគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានគតិយុត្តិសំខាន់ៗ ឆ្លើយតបនឹងអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនិងនារីភេទ | ០២ | ០១ | ០១ | ក្រសួងកិច្ចការនារី |
| ៣២ | កិច្ចប្រជុំផ្សព្វផ្សាយ អនុសាសន៍ណែនាំ របស់ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា និងការរៀបចំតែងតាំងគណៈកម្មការតាមបណ្តាលវត្តនានា | ០១ | ០២ | ០១ | មន្ទីរធម្មការនិងសាសនា |
| ៣៣ | ចូលរួមសិក្ខាសាលាបូកសរុបលទ្ធផលការងាររយៈពេល ០៩ខែ ឆ្នាំ២០២៣ និងលើកទិសដៅការងារ ស្តីពីការរៀបចំគម្រោងសេវាសង្គម ឆ្នាំ២០២៤ | ០១ | ០១ | ០០ | រដ្ឋបាលខេត្តកោះកុង |
| ៣៤ | ចូលរួមសិក្ខាសាលាស្តីពី« វិធីសាស្ត្រអភិវឌ្ឍផលិតភាព និងគុណភាព | ០១ | ០១ | ០០ | រដ្ឋបាលខេត្តកោះកុង |
| ៣៥ | ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីបច្ចេកទេសស៊ើបអង្កេតបណ្តឹង និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ | ០៣ | ០២ | ០០ | ក្រសួងមហាផ្ទៃ |
| ៣៦ | កិច្ចប្រជុំផ្សព្វផ្សាយស្តីពីកាចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៥ឆ្នាំ២០២៤និងផ្សព្វផ្សាយលទ្ធផលបណ្តោះអាសន្នស្តីពីការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោត | ០១ | ០១ | ០០ | លេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកោះកុង |
| ៣៧ | ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការជំរុញវិនិយោគ និងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ | ០១ | ០១ | ០០ | មន្ទីរទេសចរណ៍ខេត្តកោះកុង |
| ៣៨ | វគ្គបណ្តុះបណ្តាល ស្តីពីការងាររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ០១ | ០៥ | ០០ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

| | | | | | |
|---|---|---|---|---|---|
| ៣៩ | ចូលរួមក្នុងពិធីបើកសិក្ខាសាលាស្តីពី « ការកំណត់អត្តសញ្ញាណ និង ការផ្សព្វផ្សាយផលិតផលសក្តានុពលកម្ពុជា » | ០១ | ០១ | ០០ | **មន្ទីរពាណិជ្ជកម្ម ខេត្តកោះកុង** |
| ៤០ | សិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផល ប្រេងកាត ផ្នែកដោនស្ទ្រីម ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាព លិខិតអនុញ្ញាត និងអាជ្ញាបណ្ណសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម និងប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសម្រាប់ផ្នែកដោនស្ទ្រីម ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត | ០១ | ០១ | ០០ | **រដ្ឋបាល ខេត្តកោះកុង** |
| ៤១ | សិក្ខាសាលាឆ្លុះបញ្ចាំង ស្តីពីការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រយៈពេល ៩ខែ ក្នុងឆ្នាំ២០២៣ | ០២ | ០១ | ០០ | **ក្រសួងមហាផ្ទៃ** |
| ៤២ | វគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ជូនដល់សមាជិកនៃគណៈកម្មាធិការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ខេត្តកោះកុង | ០១ | ០៣ | ០០ | **រដ្ឋបាល ខេត្តកោះកុង** |
| ៤៣ | វគ្គបណ្តុះបណ្តាល ស្តីពីសៀវភៅណែនាំការអនុវត្តគោលនយោបាយភូមិឃុំសង្កាត់ មានសុវត្ថិភាព | ០៣ | ០៤ | ០០ | **រដ្ឋបាល ខេត្តកោះកុង** |
| ៤៤ | វគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឌីជីថល នៃកម្មវិធីវាយតម្លៃមូលនិធិគាំទ្រការផ្តល់សេវាឃុំ សង្កាត់ នៃគម្រោងអាហារូបត្ថម្ភនៅកម្ពុជា | ០៥ | ០១ | ០០ | **គ.ជ.អ.ប** |
| ៤៥ | វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពការងារផ្តល់សេវារដ្ឋបាលក្នុងវិស័យដឹកជញ្ជូនផ្លូវគោកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | ០១ | ០២ | ០១ | **ក្រសួងមហាផ្ទៃ** |
| ៤៦ | កិច្ចប្រជុំផ្សព្វផ្សាយផែនការថវិកាប្រចាំឆ្នាំ២០២៤ របស់រដ្ឋបាលឃុំទាំង៤ ជាមួយប្រជាពលរដ្ឋ | ០៤ | ០២ | ០០ | **រដ្ឋបាលស្រុក** |
| ៤៧ | វគ្គក្រឹត្យការមូលដ្ឋានជំនាន់ទី៧ ឆ្នាំ២០២៣ | ០២ | ០២ | ០០ | **សាលាជាតិមូលដ្ឋាន** |
| ៤៨ | សិក្ខាសាលាត្រួតពិនិត្យលទ្ធផលការងារប្រចាំឆ្នាំ២០២៣ នៃគម្រោងអាហារូបត្ថម្ភនៅកម្ពុជា | ០២ | ០១ | ០១ | **គ.ជ.អ.ប** |
| ៤៩ | សិក្ខាសាលាស្តីពី« យុទ្ធសាស្ត្រសហគមន៍សាលារៀនលើកទី២ » | ០៣ | ០១ | ០០ | **ក្រសួងអប់រំ** |
| ៥០ | សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីអគ្រានុកូលដ្ឋាន ស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម | ០១ | ០២ | ០០ | **ក្រសួងមហាផ្ទៃ** |
| **សរុប** | | **៨២** | **១២៦** | **១៩** | |

**១.៧.៣ ការគ្រប់គ្រង ការចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលស្រុក**

- បានរៀបចំបញ្ជីវត្តមានរបស់គណៈអភិបាល នាយក នាយករងរដ្ឋបាល ប្រធាន អនុប្រធាន មន្ត្រីការិយាល័យ/អង្គភាព មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីស្ម័គ្រចិត្ត សម្រាប់ចុះវត្តមានប្រចាំថ្ងៃ និងបូកសរុបបញ្ជីវត្តមានប្រចាំខែ ។
- បានរៀបចំបេសកកម្ម ជូនមន្ត្រីរដ្ឋបាលស្រុក បាន ចំនួន **៤៦៦** បេសកកម្ម។

**១.៧.៤ ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន**

- បានរៀបចំឯកសារប្រវត្តរូបសង្ខេប មន្ត្រីជាប់កិច្ចសន្យា សម្រាប់ឆ្នាំ២០២៣ របស់រដ្ឋបាលស្រុកកោះកុង ជូនរដ្ឋបាលខេត្តកោះកុង។

- បានរៀបចំឯកសារបញ្ជូនជីវប្រវត្តិមន្ត្រីរាជការ សម្រាប់ឆ្នាំ២០២៣ និងតារាងបញ្ជីបច្ចុប្បន្នភាពមន្ត្រីរាជការ សម្រាប់ឆ្នាំ២០២៣ ជូនរដ្ឋបាលខេត្តកោះកុង។

- បានរៀបចំដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមវេនប្រចាំឆ្នាំ២០២៣ ជូនមន្ត្រីរាជការស៊ីវិលសាលាស្រុកកោះកុង ចំនួន០២នាក់ ជូនសាលាខេត្តកោះកុង ។

- បានរៀបចំតារាងបញ្ជីឈ្មោះមន្ត្រីរាជការ ដែលត្រូវបានបំពាក់មេដាយ និងគ្រឿងឥស្សរិយយស ជូនរដ្ឋបាលខេត្តកោះកុង។

- បានរៀបចំសេចក្តីសម្រេច ស្តីពីការទទួលស្គាល់ការកែសម្រួលគណៈកម្មាធិការ គណៈកម្មការ និងតួនាទីភារកិច្ច ជូនការិយាល័យ អង្គភាព ចំណុះរដ្ឋបាលស្រុកកោះកុង ។

- បានរៀបចំតារាងស្ថិតិទិន្នន័យមន្ត្រីរាជការតម្លើងថ្នាក់ និងឋានន្តរស័ក្តិ ឆ្នាំ២០២៣ និងតារាងបញ្ជីរាយនាមមន្ត្រីរាជការលុបឈ្មោះ និងចូលនិវត្តន៍ ឆ្នាំ២០២៣ និងឆ្នាំ២០២៤ ជូនរដ្ឋបាលខេត្តកោះកុង។

- បានរៀបចំសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃ ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងរៀបចំដីកា ដល់មន្ត្រីរាជការ ។

- បានរៀចំដីកា ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ។

-បានរៀបចំឯកសារការសុំពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណុំឯកសារ នៃការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិល ឆ្នាំ២០២៣ ជូនមន្ទីរមុខងារសាធារណៈខេត្តកោះកុង បានចំនួន ០៨ លើក។

- បានរៀបចំឯកសារសម្រាប់ដំណើរការប្រឡងជ្រើសរើសសិស្សនិសិត្សឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌរដ្ឋបាលស្រុកកោះកុង ។

- បានរៀចំដីកា ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ មុនការកំណត់។

- បានរៀបចំដីកា ស្តីពីការបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល របស់រដ្ឋបាលស្រុកកោះកុង ។

- បានរៀបចំសំណើសុំផ្លាស់ប្តូរមន្ត្រីជាប់កិច្ចសន្យាចំនួន០១រូប ជូនរដ្ឋបាលខេត្តកោះកុង ។

- បានរៀបចំតារាងបញ្ជីបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល និងតារាងប្រភេទក្របខ័ណ្ឌ ជូនរដ្ឋបាលខេត្តកោះកុង

- បានរៀបចំសំណើសុំពិនិត្យ និងទទួលស្គាល់លើលទ្ធផលប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលស្រុកកោះកុងនាសម័យប្រឡងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ និងស្នើសុំសលាកបត្រព័ត៌មានមន្ត្រីរាជការ សម្រាប់ផ្តល់ជូនបេក្ខជន ចំនួន០២រូប ដែលបានប្រឡងជាប់ជាស្ថាពរ។

- បានរៀបចំសំណុំឯកសារ សលាកប័ត្រព័ត៌មានមន្ត្រីរាជការស៊ីវិល ជូនរដ្ឋបាលខេត្តកោះកុង។

- បានរៀបចំឯកសារដំឡើងថ្នាក់ និងឋានន្តរស័ក្តិ តាមវេនអតីតភាពការងារ ជូននាយករដ្ឋបាល និងស្មៀឃុំ ប្រចាំឆ្នាំ២០២៤ នៃរដ្ឋបាលស្រុកកោះកុង ជូនរដ្ឋបាលខេត្តកោះកុង ។

- បានរៀបចំឯកសារស្នើសុំតែងតាំង និងប្រគល់ភារកិច្ច ជូមន្ត្រីរាជការ នៃរដ្ឋបាលស្រុកកោះកុង។

- បានរៀបចំតារាងស្ថិតិមន្ត្រីរាជការបម្រើការងារនៅរដ្ឋបាលស្រុកកោះកុង ស្ថិតិថ្នាក់ដឹកនាំដែលមានអាយុក្រោម៣៥ឆ្នាំ និងមានមុខតំណែងចាប់ពីអនុប្រធានការិយាល័យរហូតដល់អភិបាលស្រុក និងតារាងស្ថិតិមន្ត្រីរាជការនៃរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុកកោះកុង បានចំនួន០២លើក ។

- បានរៀបចំតារាងបច្ចុប្បន្នភាពក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក នាយក នាយករង ក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ជូនរដ្ឋបាលខេត្តកោះកុង។

## ១.៨ ការងារការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់

### ១.៨.១ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគស្រុក

នៅក្នុងឆ្នាំ២០២៣ នេះ ការិយាល័យផែនការ និងគាំទ្រឃុំ-សង្កាត់ នៃរដ្ឋបាលស្រុកកោះកុង បានរៀបចំការងារកសាងប្រតិទិនកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦) ដែលត្រូវបានអនុម័តនាសម័យប្រជុំសាមញ្ញលើកទី៤៤ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣។ ជាមួយគ្នានេះ ដំណើរការនៃរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦) របស់រដ្ឋបាលស្រុកកោះកុង បានរៀបចំដល់ជំហានទី៣ គឺការរៀបចំកែសម្រួល និងធ្វើបច្ចុប្បន្នភាពឡើងវិញ និងបានរៀបចំសេចក្តីព្រាង កម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦)។

**តារាងទី១៤៖ ការកសាងផែនការអភិវឌ្ឍន៍**

| ជំហាន | លទ្ធផលអនុវត្តជាក់ស្តែង |
|---|---|

| | |
|---|---|
| ជំហានទី១៖ការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ស្រុក | |
| ជំហានទី២៖ការរៀបចំ និងការចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ស្រុក | |
| ជំហានទី៣៖ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ស្រុក | |

**តារាងទី១៥៖ កម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក**

| ជំហាន | លទ្ធផលអនុវត្តជាក់ស្តែង |
|---|---|
| **ជំហានទី១៖**ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក | បានអនុវត្តសម្រេច ១០០% |
| **ជំហានទី២៖**ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក | បានអនុវត្ត ៩០% |
| **ជំហានទី៣៖**ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក | មិនទាន់បានអនុវត្ត |

### ១.៨.២ គម្រោងវិនិយោគស្រុក

ក្នុងឆ្នាំ២០២៣ នេះ រដ្ឋបាលស្រុកកោះកុង មានគម្រោងអភិវឌ្ឍន៍ចំនួន ០១គម្រោង ដែលជាគម្រោងលើការងារ ជួសជុលផ្លូវបេតុងអាមេចំនួន ០១ខ្សែ ដែលមានប្រវែង ៣.០៣៥ម៉ែត្រ ទទឹង ៣ម៉ែត្រ កម្រាស់ ១២០ម.ម ដែលបានសិក្សាផលប៉ះពាល់ដីធ្លី និងបរិស្ថាន ចប់ជាស្ថាពរ នៅក្នុងឃុំកោះកាពិ ស្រុកកោះកុង។ ជាលទ្ធផល នៃការសិក្សាតម្លៃប៉ាន់ស្មានសម្រាប់ការងារនេះទាំងមូល គឺខាងជំនាញបច្ចេកទេសខេត្តកោះកុង បានសិក្សាពីលទ្ធភាពថវិកានៃគម្រោងការងារជួសជុលនេះបានប្រវែង ១.០០៥ម៉ែត្រ នៃប្រវែងសរុប ដែលប្រើប្រាស់ថវិកាចំនួន **៦៥២,១៧៩,០០០រៀល (ប្រាំមួយរយហាសិបពីរលាន មួយរយចិតសិបប្រាំបួនពាន់រៀលគត់)** ។

**តារាងទី១៦៖ ការអនុវត្តគម្រោងវិនិយោគស្រុក**

| ល.រ | ផ្នែក | សរុប | បានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |
| ១ | សេដ្ឋកិច្ច | ០១ | ០០ | ០១ | ០០ |
| ២ | សង្គមកិច្ច | ០០ | ០០ | ០០ | ០០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ | ០០ | ០០ | ០០ | ០០ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ០៣ | ០០ | ០០ | ០៣ |
| **សរុប** | | **០៤** | **០០** | **០១** | **០៣** |

### ១.៨.៣ការអនុវត្តន៍ផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប

**តារាងទី១៧៖ លទ្ធផលសម្រេចបាន**

| លេខកូដ | ឈ្មោះសកម្មភាព | ស្ថានភាព | %សម្រេច | %ចំណាយ |
|---|---|---|---|---|
| 2.6.1.13 | អភិវឌ្ឍសមត្ថភាពអំពីការងារគណនេយ្យភាពសង្គមដល់អង្គភាពផ្តល់សេវា និងអ្នកពាក់ព័ន្ធនានាដោយក្រុង ស្រុក ខណ្ឌ | បានរៀបចំ | ១០០% | ១០០% |
| 2.6.1.15 | រៀបចំផលិត និងបិតផ្សព្វផ្សាយទិន្នន័យលទ្ធផលការងារ (Post-On) ដោយក្រុង ស្រុក ខណ្ឌ | បានរៀបចំ | ១០០% | ១០០% |
| 4.1.3.8 | ប្រមូលទិន្នន័យមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ | បានអនុវត្ត | ១០០% | ១០០% |

### ១.៨.៤ ការគាំទ្ររដ្ឋបាលឃុំ សង្កាត់

**ក. ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់**

– បានចុះគាំទ្រ តាមដាន និងជម្រុញ លើការងារដំណើរការ នៃការកសាង និងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤-២០២៦) របស់រដ្ឋបាលឃុំទាំងបួន បានចំនួន ០២លើក ដែលក្នុងនោះលើកទី១ បានចុះពិនិត្យមើលលើការរៀបចំនូវប្រតិទិននៃការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦) និងលើកទី២ ចុះគាំទ្រ និងតាមដាន លើដំណើរការ នៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦)។

– បានគាំទ្រ ជម្រុញ និងតាមដានការងារ ដំណើរការនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦) និងការកសាងកម្មវិធីអភិវឌ្ឍរយៈពេល៥ឆ្នាំ (២០២៣-២០២៧) របស់រដ្ឋបាលឃុំទាំង៤ ។

– បានចូលរួមសិក្សាផលប៉ះពាល់ដីធ្លី បរិស្ថាន និងដំណាំ នៃគម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហមចំនួន ០១ខ្សែនៅឃុំតាតៃក្រោម និង០១ខ្សែ នៅឃុំត្រពាំងរូង និងផ្លូវបេតុងអាមេចំនួន ៣ខ្សែ នៅឃុំជ្រោយប្រស់ ០១ខ្សែ និងឃុំកោះកាពិ ០២ខ្សែ បេតុងអាមេ ០១ខ្សែ និងបេតុងមានជើង ០១ខ្សែ។

– បានចូលរួមបើកសំណើដេញថ្លៃគម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហមចំនួន ០១ខ្សែនៅឃុំតាតៃក្រោម និង០១ខ្សែ នៅឃុំត្រពាំងរូង និងផ្លូវបេតុងអាមេចំនួន ៣ខ្សែ នៅឃុំជ្រោយប្រស់ ០១ខ្សែ និងឃុំកោះកាពិ ០២ខ្សែ បេតុងអាមេ ០១ខ្សែ និងបេតុងមានជើង ០១ខ្សែ។

– បានចូលរួមពិនិត្យគម្រោងសាងសង់ផ្លូវមេតុងអាមេចំនួន ០១ខ្សែ ប្រវែង ១០០ម៉ែត្រ និងផ្លូវលំក្រាលក្រួសក្រហម ១ខ្សែ មានប្រវែង ៥០០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រែកអង្គុញ ឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង ដែលប្រើប្រាស់ថវិកាមូលនិធិឃុំ សម្រាប់ឆ្នាំ២០២៣។

– បានចុះត្រួតពិនិត្យ តាមដាន និងគាំទ្រការអនុវត្តការងារ របស់រដ្ឋបាលឃុំត្រពាំងរូង។

– បានពិនិត្យដំណើរការ នៃការអនុវត្ត គម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហមចំនួន ០១ខ្សែនៅឃុំតាតៃក្រោម និងឃុំត្រពាំងរូង ០១ខ្សែ ផ្លូវបេតុងអាមេនៅឃុំជ្រោយប្រស់ ០១ខ្សែ និងឃុំកោះកាពិ ០២ខ្សែ បេតុងអាមេ ០១ខ្សែ និងបេតុងមានជើង ០១ខ្សែ។

**តារាងទី១៨៖ ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់**

| ល.រ | ការបរិយាយ | ចំនួនឃុំ ០៤ ឃុំ | |
|---|---|---|---|
| | | បានបញ្ចប់ | មិនទាន់បញ្ចប់ |
| ១ | **ជំហានទី១៖**ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋាន | ០៤ | ០០ |
| ២ | **ជំហានទី២៖**ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល | ០៤ | ០០ |
| ៣ | **ជំហានទី៣៖**ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិល | ០០ | ០៤ |

**ខ. ការតាមដាន និងការគាំទ្រលើការរៀបចំ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់**

**តារាងទី១៩៖ ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់**

| ល.រ | ផ្នែក | សរុប | បានបញ្ចប់ | | |
|---|---|---|---|---|---|
